**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

PHNOM PENH WATER SUPPLY AUTHORITY

លេខ ១៧៧១...សរ.ភ.ណ

ថ្ងៃអង្គារ ៩កើត ខែភទ្របទ ឆ្នាំ ច សំរិទ្ធស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ថ្នាំប្រតិករគីមី និងGLASSWARE។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ត្រឹមវេលាម៉ោង១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ១២០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួលសំណើពិគ្រោះថ្លៃគឺ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១៥:៣០នាទី។

កាលបរិច្ឆេទបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១៥:៣០នាទី នៅអគារអង្គភាពលទ្ធកម្ម (ជាន់ទី១) របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសាពិគ្រោះថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

បណ្ឌិត. **ជា វិសុទ្ធ**

<u>ចម្លងជូនៈ</u>

- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- -អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- -ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥)-២៣- ៧២៤ ០៤៦ / (២៣) ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh